មហារីកប្រមោយដៃស្បូន

អាចហៅថាមហារីកនៃប្រមោយដៃស្បូន

អ្វីទៅដែលស្ត្រីត្រូវតែដឹង

អ្វីទៅដែលខ្ញុំត្រូវកត់សំគាល់?

រោគមហារីក ប្រមោយដៃស្បូនពិបាករកឃើញណាស់។
វាអាចកើតដោយគ្មានរោគសញ្ញាសោះរហូតដល់មហារីកនេះវារាលដាលតែម្តង។ អ្វីៗដែលអ្នកមានអារម្មណ៍ ឬក៏ឃើញប្លែកនៅលើខ្លួនអ្នក
វាហាក់ដូចជាមិនមានអ្វី ទាក់ទងនឹងរោគមហារីកសោះ។
រោគសញ្ញាខាងក្រោមមិនមានន័យថាវាអាចបង្កើតរោគមហារីកទេ
ក៏ប៉ុន្តែអ្នកគួរតែនិយាយប្រាប់រោគសញ្ញាទាំងនោះទៅវេជ្ជបណ្ឌិតជាបន្ទាន់៖

- មានអារម្មណ៍ណែនឬក៏ហើមនៅក្នុងពោះដោយសារមានទឹកលើសចំនួន។ ហើមនេះ មានលក្ខណៈខុសផ្លែកពីមករដូវរាល់ខែ។
- ឡើងឬស្រក់ទម្ងន់ដោយឥតមូលហេតុ។
- ឡើងធំជាងមុននៅកន្លែងក្រពះ។
- ធ្លាក់ឈាមឬក៏ ធ្លាក់សពីរន្ធយោនី (ដែលខុសផ្លែកពីមករដូវតាមធម្មតា)
- មានបញ្ហាក្រពះមិនចេះស្រាកស្រាណ។ អ្នកមានការឈឺចុកចាប់ខ្សល់ក្នុងពោះឬក៏ ចង់ក្អួត។
- ឈឺខ្នងឬឈឺជើង៕

តើអ្វីទៀតដែលធ្វើឲ្យជំងឺនេះកាន់តែមានគ្រោះថ្នាក់ថែម?

អ្វីដែលបណ្តាលឲ្យមានគ្រោះថ្នាក់ក្នុងជំងឺមហារីកប្រមោយដៃស្បូន
មានដូចតទៅ៖

- មានអាយុលើសពី៥០ឆ្នាំ។
- អ្នកមានមករដូវលើកដំបូងនៅវ័យក្មេង (មុននឹងអាយុ១២ឆ្នាំ)។
- មិនធ្លាប់មានផ្ទៃពោះ ឬក៏សំរាលកូន។
- សំរាលកូនដំបូងបន្ទាប់ពីមានអាយុលើសពី៣០ឆ្នាំ។
- ពិសារបារី។
- មិនមានផ្ទៃពោះ។
- មានជំងឺមហារីកដោះ ក្នុងពេលបច្ចុប្បន្ននេះ ឬក៏កាលពីមុនមក។
- មានសមាជិកណាមួយនៅក្នុងក្រុមគ្រួសារ ធ្លាប់មានជំងឺមហារីកដោះ មហារីកនៅចុងពោះវៀន ឬក៏មហារីកប្រមោយដៃស្បូន។
- មានទំងន់ធំធាត់ខ្លាំងពេក។
- បានប្រើការព្យាបាលជាយូរពេល នឹងអ័រម៉ូនជាជំនួយនៃកោសិកាណាមួយក្នុងខ្លួនហៅ អែស្ត្រូយឺន។ការព្យាបាលតាមរបៀបអែស្ត្រូយឺន
ឬក៏តាមរបៀបអ័រម៉ូន។

តើខ្ញុំអាចធ្វើដូចម្តេចទៅ ដើម្បីជួយរកឲ្យឃើញរោគមហារីកប្រមោយដៃស្បូន ឲ្យបានទាន់ពេល ?

- ស្ត្រីដែលមានការរួមដំណេក ឬក៏ស្ត្រីដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវតែទៅពិនិត្យស្បូន (ធ្វើជាប់តេស៍)ជារៀងរាល់ឆ្នាំ។
- ពេលពិនិត្យស្បូនវេជ្ជបណ្ឌិតនឹងស្ទាបសរីរាង្គរបស់ស្ត្រីភេទ

ពិនិត្យមើលទំហំនិងរាងរៅ
ប៉ុន្តែមហារីកប្រមោយដៃស្បូនភាគច្រើនពិបាករកឲ្យឃើញមុនពេលណាស់ ។ មានការពិបាកពីព្រោះប្រមោយដៃស្បូននៅកប់ជ្រៅពេកក្នុងខ្លួន
ហើយវេជ្ជបណ្ឌិតមិនអាចស្ទាបឃើញដោយស្រួលៗទេ។
ការពិនិត្យស្បូន(ធ្វើជាប់តេស៍)អាចឲ្យជួយរកឃើញមហារីកកស្បូនមុន

តែការពិនិត្យស្បូននេះមិនអាច ជួយឲ្យរក
ឃើញមហារីកប្រមោយដៃស្បូនមុនបានឡើយ។

- មានការពិនិត្យផ្សេងៗទៀតដែលអាចជួយរក
រោគមហារីកប្រមោយដៃស្បូននេះ
តែជួនកាលវាមិនអាចរកឃើញឲ្យបានមុនពេលទេ។
អ្នកហើយនិងវេជ្ជបណ្ឌិតរបស់អ្នកពិភាក្សារគ្នាអំពីការពិនិត្យដែលល្អប្រសើរចំពោះអ្នក។
តែត្រូវជាការយោកយល់ទៅតាមអាយុនឹងប្រវត្តិសុខភាពរបស់អ្នក។

ការខុសផ្លែកដែលអ្នកបានកត់សំគាល់អំពីខ្លួនអ្នក។

ការពិនិត្យគឺរួមទាំងពិនិត្យឈាមផ្សេងៗ
និងឆ្លុះអុលត្រាសោនដោយមិនមានការឈឺចុកចាប់។

តទំព័រខាងក្រោយ



ព្យាបាលរោគមហារីកប្រមោយដៃស្បូនតាមវិធីណាខ្លះ?

វេជ្ជបណ្ឌិតអាចព្យាបាលរោគមហារីកប្រមោយដៃស្បូនតាមលក្ខណៈច្រើនយ៉ាង៖

- ការវះកាត់គឺយកប្រមោយដៃស្បូនម្ខាងឬក៏ទាំងពីរខាង យកដៃស្បូន និងស្បូនចេញ។
  កាត់យកតែប្រមោយណាដែលមានមហារីកពេលដែលរកឃើញមុន។
  នេះអាចជួយ ឲ្យស្ត្រីក្មេងៗនឹងអាចមានកូនបាន។
- បន្ទាប់ពីការវះកាត់ ព្យាបាលតាម
  ថ្នាំគីម៉ូត្រូវតែប្រណិបត្តិលើមហារីកដែលនៅ សល់។
- នៅក្នុងសហរដ្ឋអាមេរិកការព្យាបាលតាមកម្មវិធី
  មិនសូវមានប្រើជាញឹកញាប់ទេ។

តើខ្ញុំអាចរស់បានរបៀបណាក្រោយពីមានជំងឺមហារីកប្រមោយដៃស្បូននេះ ?

- ស្ត្រីភាគច្រើន (៩០ភាគរយ)នឹងរស់បាន៥ឆ្នាំឬក៏ច្រើនជាងនេះ
  បើសិនជារកឃើញ
  រោគមហារីកប្រមោយដៃស្បូននេះឲ្យបានមុនពេល។
- ស្ត្រីភាគច្រើនស្លាប់ដោយសាររោគមហារីកប្រមោយដៃស្បូននេះជាង
  រោគមហារីកលើប្រដាប់បន្តពូជផ្សេងៗទៀត។

និយាយប្រាប់ វេជ្ជបណ្ឌិតបើអ្នកមានរោគសញ្ញាទាំងនេះ។ ពិគ្រោះជាមួយ
វេជ្ជបណ្ឌិតរបស់អ្នកបើ សិនជាអ្នកមានសំនួរអ្វីទៀតអំពីសុខភាពរបស់អ្នក
ឬក៏ការព្យាបាល របស់អ្នក។ វេជ្ជបណ្ឌិតរបស់ អ្នកអាចឲ្យពត៌មានបន្ថែមទៀត
ស្តីអំពីរោគមហារីកប្រមោយដៃស្បូននេះ។



ស្ត្រីដែលមានការរួមដំណេក
ឬក៏ស្ត្រីដែលមានអាយុលើសពី១៨ឆ្នាំ ត្រូវតែទៅពិនិត្យ

ពត៌មាន: *California Cancer Registry (CDHS/CSS)*

American Cancer Society Facts and Figures 2004.

ពត៌មានទាំងនេះអាចផ្តិតចេញពីក្រសួងរាក់សារសុខភាពស្ត្រីប្រចាំរដ្ឋកាលី
www.dhs.ca.gov/director/owh.

Arnold Schwarzenegger, Governor
State of California

S. Kimberly Belshé, Secretary
Health and Human Services Agency

Sandra Shewry, Director
Department of Health Services

Revised 11/04